# កាត់បន្ថយផលប៉ះពាល់ធំនប់
# នៅតាមដងទន្លេសេសានដែលហូរឆ្លងកាត់ព្រំដែន
# នៅភូមិភាគឦសាននៃប្រទេសកម្ពុជា

ការពិនិត្យឡើងវិញនូវ *ការវាយតម្លៃត្រួសៗលើផលប៉ះពាល់បរិស្ថានទន្លេសេសាននៅខាងប្រទេសកម្ពុជា ដោយសារការអភិវឌ្ឍន៍វារីអគ្គិសនីនៅក្នុងប្រទេសវៀតណាម* (ឯកសារខែ កក្កដា ឆ្នាំ ២០០៧)



ការពិនិត្យឡើងវិញ និង ការបកស្រាយត្រូវបានរៀបចំសម្រាប់

សម្ព័ន្ធទន្លេកម្ពុជា

ភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០០៨

**សម្ព័ន្ធទន្លេកម្ពុជា**

**River Coalition in Cambodia**

# សម្ព័ន្ធទន្លេកម្ពុជា

*សម្ព័ន្ធរវាងអង្គការសង្គមស៊ីវិលនានាដែលធ្វើការដើម្បីការពារ និងស្តារ ឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីទន្លេ និងជីវភាពដែលពឹងផ្អែកទៅលើទន្លេ នៅក្នុងប្រទេសកម្ពុជា*

# Rivers Coalition in Cambodia

*An Alliance of Civil Society Organizations Working to Protect and Restore River Ecosystems and River-based Livelihoods in Cambodia*

***វិធានការកាត់បន្ថយនិងកែលម្អនានានឹងត្រូវបានអនុវត្តតាមរយៈគណៈកម្មាធិការប្រើប្រាស់ទន្លេសេសាន ។ គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និង គណៈកម្មាធិការជាតិទន្លេមេគង្គវៀតណាម និង ត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរស្តីពីការប្រើប្រាស់ទឹកសម្រាប់ទន្លេសេសាន និង ទន្លេស្រែពក ។***

( ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ទន្លេសេសាន ខែ កក្កដា ឆ្នាំ ២០០៧)

## មាតិកានៃការពិនិត្យឡើងវិញ EIA

១: សេចក្តីផ្តើម

២: សេចក្តីសង្ខេបអំពីផលប៉ះពាល់ទំនប់សេសាននៅខ្សែទឹកខាងក្រោម

៣: ការពិនិត្យឡើងវិញនូវអនុសាសន៍ EIA ស្តីពីការកាត់បន្ថយនិងការផ្តល់សំណង

៤: សេចក្តីសង្កេតចុងក្រោយ

ឧបសម្ព័ន្ធ ១: ព័ត៌មានបច្ចុប្បន្នភាពស្តីពីទន្លេសេសាន (ខែ តុលា - ធ្នូ ឆ្នាំ ២០០៧)

## ១: សេចក្តីផ្តើម

យើងខ្ញុំបានពិនិត្យឡើងវិញរបាយការណ៍ខាងក្រោមនេះ:

១. ***ការវាយតម្លៃត្រួសៗលើផលប៉ះពាល់បរិស្ថានទន្លេសេសាននៅខាងប្រទេសកម្ពុជា ដោយសារការអភិវឌ្ឍន៍ វារីអគ្គិសនីនៅក្នុងប្រទេសវៀតណាម*** របាយការណ៍ចុងក្រោយ ខែ កក្កដា ឆ្នាំ ២០០៧ និង

២. ***ការវាយតម្លៃផលប៉ះពាល់បរិស្ថានទន្លេសេសាននៅខាងប្រទេសកម្ពុជា ដោយសារការអភិវឌ្ឍន៍ វារីអគ្គិសនីនៅក្នុងប្រទេសវៀតណាម*** របាយការណ៍ចុងក្រោយ ខែ ធ្នូ ឆ្នាំ ២០០៦ ។

របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ទាំងពីរត្រូវបានរៀបចំសម្រាប់ម្ចាស់និងអ្នកអភិវឌ្ឍគម្រោង ពោលគឺអគ្គិសនីវៀតណាម ដោយសហគ្រាសពិគ្រោះការងារវិស្វកម្មណ័រឌិក SWECO Groner ដោយមានការចូលរួមពីវិទ្យាស្ថានទឹកណ័រវ៉េស NIVA និង សហគ្រាសពិគ្រោះការងារណ័រឌិកពីរទៀតដែលធ្វើការងារនៅក្នុងប្រទេសវៀតណាម ពោលគឺ ENVIRO-DEV និង ENS Consult ។ ចាប់ពីត្រង់នេះទៅ យើងនឹងហៅរបាយការណ៍ឆ្នាំ ២០០៧ ថា "របាយការណ៍ EIA ។"

យើងបានដាក់ការពិនិត្យឡើងវិញរបស់យើងលើរបាយការណ៍ EIA ចុះខែ ធ្នូ ឆ្នាំ ២០០៦ ជូនអាជ្ញាធរពាក់ព័ន្ធកម្ពុជានិងវៀតណាម ដើម្បីពិនិត្យពិចារណា នៅក្នុងខែ កក្កដា ឆ្នាំ ២០០៧ ។ **[ភ្ជាប់ទៅរបាយការណ៍នេះនៅលើគេហទំព័ររបស់វេទិកាអង្គការមិនមែនរដ្ឋាភិបាល ។]** បន្ទាប់មក យើងបានទទួលរបាយការណ៍ EIA ចុងក្រោយ ចុះខែ កក្កដា ឆ្នាំ ២០០៧ និង ដែលត្រូវបានដាក់ចំណងជើងឡើងវិញថា "ការវាយតម្លៃត្រួសៗលើផលប៉ះពាល់បរិស្ថាន ។" យើងមិនឃើញមានការកែប្រែធំដុំទេនៅក្នុងរបាយការណ៍ក្រោយនេះ ។

គោលបំណងនៃការពិនិត្យឡើងវិញ EIA នេះ គឺមិនមែនសំដៅសុំឱ្យមាន "ការកែលម្អ" ចំពោះរបាយការណ៍ EIA ទន្លេសេសានទេ ។ ដោយមានទំនប់វារីអគ្គិសនីធំៗបី ដែលកំពុងដំណើរការនៅខ្សែទឹកខាងលើទន្លេសេសាន (ទំនប់យ៉ាលី ទំនប់សេសាន ៣ និង ទំនប់សេសាន ៣A) និង ទំនប់វារីអគ្គិសនីពីរទៀតដែលកំពុងសាងសង់ (ទំនប់សេសាន ៤ និង ទំនប់ប្លៃក្រុង (Pleikrong)) គោលដៅនៅពេលនេះគប្បីផ្តោតលើការកាត់បន្ថយ និង ការផ្តល់សំណងសម្រាប់ សហគមន៍រងផលប៉ះពាល់នានានៅខ្សែទឹកខាងក្រោមក្នុងប្រទេសកម្ពុជា ។

អស់រយៈពេលជាង ១០ ឆ្នាំហើយតាំងពីពេលដែលអគ្គិសនីវៀតណាម (EVN) បានសាងសង់ទំនប់វារីអគ្គិសនីយ៉ាលីនៅលើទន្លេសេសានខាងលើ – ដែលជាដៃទន្លេដ៏ធំមួយនៃទន្លេមេគង្គដែលចែកគ្នាដោយប្រទេសវៀតណាម

និងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ ទំនប់យ៉ាលី ទំនប់សេសាន ៣ និង ទំនប់សេសាន ៣A កំពុងបង្កើតអគ្គិសនីសម្រាប់អ្នកប្រើប្រាស់ថាមពលនៅក្នុងប្រទេសវៀតណាម ខណៈដែលផលប៉ះពាល់ខាងបរិស្ថានដ៏ធ្ងន់ធ្ងរបំផុតរបស់ទំនប់ទាំងនេះនៅតែមិនទាន់បានសងនិងកាត់បន្ថយ។ របាយការណ៍ EIA អះអាងបញ្ជាក់ថាប្រតិបត្តិការនៃទំនប់យ៉ាលីបានបន្ទុចបង្អាក់យ៉ាងធ្ងន់ធ្ងរនូវលំហូរខ្សែទឹកខាងក្រោមទន្លេសេសាននៅក្នុងប្រទេសកម្ពុជា ដែលនៅទីនោះប្រជាជនជាង ២៨.០០០ នាក់ពឹងអាស្រ័យលើទន្លេនេះដើម្បីទឹកផឹក ប្រព័ន្ធស្រោចស្រពដំណាំ នេសាទ ទឹកសម្រាប់បសុសត្វ និង ការដឹកជញ្ជូន។

ដើម្បីជម្រុញការពិភាក្សាដែលមានព័ត៌មានពេញលេញ និង សកម្មភាពកែតម្រូវ របាយការណ៍ខាងក្រោមនេះផ្តល់នូវសេចក្តីសង្ខេបនិងការពិនិត្យឡើងវិញលើផលប៉ះពាល់ខ្សែទឹកខាងក្រោមរបស់ទំនប់ទាំងនេះ និងអនុសាសន៍នៃ EIA ដើម្បីកាត់បន្ថយផលប៉ះពាល់និងផ្តល់សំណង។

ដោយមានការពិនិត្យឡើងវិញ EIA នេះ គុណសម្បត្តិនៃអនុសាសន៍របស់ EIA និង អាទិភាពរបស់ប្រទេសកម្ពុជាដើម្បីកាត់បន្ថយផលប៉ះពាល់ទំនប់ តម្រូវឱ្យមានការពិភាក្សាបន្ថែមទៀតនៅក្នុងចំណោមភាគីពាក់ព័ន្ធកម្ពុជា រួមទាំងសហគមន៍រងផលប៉ះពាល់នៅក្នុងខេត្តរតនៈគិរី ជាមួយនឹងជំនួយពីគណៈកម្មាធិការប្រើប្រាស់ទន្លេសេសាន និងគណៈកម្មការទន្លេមេគង្គដែលត្រូវបានគាំទ្រដោយអង្គការសហប្រជាជាតិ។

## ២: សេចក្តីសង្ខេបអំពីផលប៉ះពាល់ទំនប់សេសាននៅខ្សែទឹកខាងក្រោមក្នុងប្រទេសកម្ពុជា

របាយការណ៍ EIA និយាយថាលំហូរទឹកទន្លេនៅខ្សែទឹកខាងក្រោមក្នុងប្រទេសកម្ពុជានឹងខ្ពស់ជាងធម្មតានៅក្នុងរដូវប្រាំង និង ទាបជាងធម្មតានៅដើមរដូវវស្សា ដែលនៅពេលបន្ទាប់នោះ នឹងមានទឹកជំនន់រយៈពេលវែង ដែលជាលទ្ធផលនៃប្រតិបត្តិការទំនប់នៅខ្សែទឹកខាងលើ។ សម្រាប់សហគមន៍នៅខ្សែទឹកខាងក្រោម ចំណុចនេះមានន័យថា:

- មានដីកាន់តែតិចសម្រាប់ធ្វើកសិកម្មតាមមាត់ទន្លេនៅក្នុងរដូវប្រាំង
- កង្វះខាតទឹកសម្រាប់ផលិតកម្មស្រូវនៅដើមរដូវវស្សា
- ហានិភ័យកាន់ខ្ពស់នៃទឹកជំនន់ធ្វើឱ្យខូចខាតដំណាំនិងទ្រព្យសម្បត្តិផ្សេងទៀតនៅក្នុងរដូវវស្សា និង
- ផលនេសាទថយចុះយ៉ាងច្រើន។

តារាង ១ ផ្តល់ជូនសេចក្តីសង្ខេបលម្អិតអំពីផលប៉ះពាល់ខាងក្រោមខ្សែទឹកដែលត្រូវបានកំណត់នៅក្នុងរបាយការណ៍ EIA។

**តារាង ១: ផលប៉ះពាល់ខាងក្រោមខ្សែទឹកនៃទំនប់អគ្គិសនីវៀតណាមលើទន្លេសេសានលើ**

| **ផលប៉ះពាល់** | **សេចក្ដីអធិប្បាយ** |
|---|---|
| **បាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ ជីវភាពរស់នៅ និង លំនៅដ្ឋាន** | របាយការណ៍ EIA ទន្លេសេសានបញ្ជាក់អះអាងថាការបញ្ចេញទឹកទំនប់យ៉ាលីពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២000 គឺមានលក្ខណៈធំគ្រប់គ្រាន់សម្រាប់បណ្ដាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរនៅតាមដងទន្លេសេសាននៅឆ្ងាយក្រោមខ្សែទឹកនៅក្នុងប្រទេសកម្ពុជា រួមទាំងការបាត់បង់អាយុជីវិត ជីវភាពរស់នៅ និង លំនៅដ្ឋាននៅក្នុងប្រទេសកម្ពុជា។ [EIA, ៦៩] |
| **កង្វះអាហារូបត្ថម្ភ** | *ក្នុងរយៈពេលវែង កង្វះអាហារូបត្ថម្ភ ជាពិសេស សម្រាប់កុមារកំពុងលូតលាស់ ... ការចុះដុនដាបស្ថានភាពសុខភាពត្រូវបានរំពឹងថាកើតឡើង ប្រសិនបើមិនមានជម្រើសប្រភពប្រូតេអ៊ីនផ្សេងជំនួសត្រី ហើយបើបន្លែតាមមាត់ទន្លេមិនអាចត្រូវបានជំនួសដោយរុក្ខជាតិផ្សេងទៀត។* [EIA, ១៤៣] |
| **បាត់បង់ផលិតកម្មស្រូវរដូវវស្សា** | *ផលិតកម្មស្រូវបានទទួលផលប៉ះពាល់អវិជ្ជមាន ដោយសារមានទឹកច្រើនពេកនៅពេលមានទឹកជំនន់ និង កំពស់ទឹកទាបនៅដើមរដូវវស្សា។*[EIA, ១៤0] |
| **ផលនេសាទថយចុះ** | *ផលនេសាទថយចុះ (ពី ១០ ដល់ ៣០ ភាគរយនៃផលនេសាទកាលពីពេលមុន) ដោយសារបរិមាណត្រីថយចុះ។ [ទំនប់វារីអគ្គិសនីយ៉ាលី គឺជាមូលហេតុចម្បងមួយនៃការថយចុះនេះ។* [EIA, ១៣៩]<br><br>*គេមិនមានការសង្ស័យឡើយថាផែនការគ្រប់គ្រងទឹកបច្ចុប្បន្ន និងដែលគ្រោងធ្វើនៅក្នុងប្រទេសវៀតណាម នឹងបណ្ដាលឱ្យមានការរលាយបាត់បង់ពូជត្រីមួយចំនួន និង សរីរាង្គរស់នៅក្នុងទឹកផ្សេងទៀតនៅក្នុងទន្លេសេសាន។* |

| | |
|---|---|
| | *ត្រីឆ្លាំងធំៗ (large catfish) ត្រំ និង ក្លាម ដោយសារត្រពាំងជ្រៅនៅក្នុងទន្លេត្រូវបានបំពេញដោយកករដី ចាប់តាំងពីពេលដែលទំនប់យ៉ាលីចាប់ផ្តើមដំណើរការ ។* [EIA, ២០]<br><br>*គេបានវាយតម្លៃថាការគ្រប់គ្រងទឹកនៃទំនប់យ៉ាលីបានកាត់បន្ថយបរិមាណត្រី ទំហំត្រី និង សមាសភាពពូជត្រីនៅក្នុងទន្លេសេសាន រហូតដល់កម្រិតមួយដែលផលនេសាទមិនអាចផ្តល់បរិមាណប្រូតេអ៊ីនចាំបាច់ ជូនប្រជាជននៅតាមដងទន្លេតទៅទៀតបានឡើយ ។ ប្រការនេះត្រូវបានរាយការណ៍ដោយប្រជាជនទាំងអស់ដែលបានសម្ភាសន៍នៅក្នុងការសិក្សានេះ និងត្រូវបានបញ្ជាក់អះអាងដោយចំនួនត្រីកាន់តែតិចពីទន្លេសេសាននៅក្នុងផ្សារត្រីនៅបានលុង ... ។ កាលពីដប់ឆ្នាំមុន ទន្លេសេសានគឺជាប្រភពត្រីដ៏សំខាន់នៅផ្សារត្រីនៅបានលុង ប៉ុន្តែ ពេលនេះត្រីមកពីទន្លេមេគង្គនៅខេត្តក្រចេះ ។* [EIA, ១៣៩] |
| **សន្តិសុខស្បៀងមានហានិភ័យ** | *ដោយសារបរិមាណត្រីថយចុះ សន្តិសុខស្បៀងមានហានិភ័យរួចទៅហើយ ។*[EIA, ១៨៦]<br><br>*បច្ចុប្បន្ននេះ គេពុំឃើញមានជម្រើសប្រភពប្រូតេអ៊ីនប្រចាំថ្ងៃជំនួសត្រីទេ ។ អ្នកភូមិមិនមានលទ្ធភាពទិញសាច់ហូបឡើយ ។ បសុសត្វត្រូវបានរក្សាទុកសម្រាប់លក់យកប្រាក់ ហើយមិនអាចហូបបានឡើយ ។* [EIA, ១៤៣] |
| **បាត់បង់ប្រូតេអ៊ីនត្រី** | *ប្រជាជនក្នុងមូលដ្ឋានពុំអាចពឹងអាស្រ័យតែលើត្រីជាប្រភពប្រូតេអ៊ីនតទៅទៀតបានឡើយ [ ដោយសារការថយចុះបរិមាណត្រី] និង ត្រូវប្រើបសុសត្វជាអាហារ ឬ ត្រូវអភិវឌ្ឍន៍ជលកសិកម្ម ។*[EIA, ១៤០] |

| | |
|---|---|
| **បាត់បង់កសិកម្មតាមមាត់ទន្លេ** | កសិកម្មតាមមាត់ទន្លេត្រូវបានកាត់បន្ថយយ៉ាងច្រើននៅពេលនេះ ដោយសារការប្រែប្រួលកំពស់ទឹកច្រើននិងទឹកជំនន់ និង ជម្រាលមាត់ទន្លេមិនរឹងមាំ ។ ការដាំដំណាំក្រោយផ្ទះក៏ជួបប្រទះឧបសគ្គផងដែរដោយសារស្ថានភាពកំពស់ទឹកមិនអាចព្យាករណ៍ជាមុន ។ ការបោះបង់ការធ្វើកសិកម្មតាមតំបន់មាត់ទន្លេជាទូទៅអាចកើនឡើង ។ សារពើរុក្ខជាតិមាត់ទន្លេដែលប្រើប្រាស់ជាអាហារដោយសហគមន៍មូលដ្ឋាន បានថយចុះ ។ [EIA, ១៤០] |
| **ការថយចុះការមានរុក្ខជាតិសម្រាប់ធ្វើជាអាហារ និង ថ្នាំសង្កូវ** | *... ការហូរច្រោះបាក់ដីបានកាត់បន្ថយការមានរុក្ខជាតិព្រៃដុះតាមមាត់ទន្លេ ដែលកាលពីពេលមុនត្រូវបានបេះសម្រាប់ធ្វើជាអាហារ និងថ្នាំសង្កូវ ។ [EIA, ១៤២]* |
| **ការហូរច្រោះបាក់ដីច្រាំងទន្លេដែលបណ្តាលមកពីការប្រែប្រួលលំហូរទឹកទន្លេ** | *ការប្រែប្រួលលំហូរទឹកនិងកំពស់ទឹករាល់ថ្ងៃ នឹងបណ្តាលឱ្យមានការហូរច្រោះបាក់ដីនៅលើតំបន់ដ៏វែងមួយនៃទន្លេខ្សែទឹកខាងក្រោម ។ ផលប៉ះពាល់នឹងមានលក្ខណៈខ្លាំងបំផុតនៅក្នុងរដូវប្រាំង ... ។ ក្នុងរយៈពេលវែង ច្រាំងទន្លេ ដើមឈើ និង ឫស្សីនឹងរំកិលធ្លាក់ទៅក្នុងទន្លេ ច្រាំងទន្លេកាន់តែចោតខ្លាំង និង រងការហូរច្រោះបាក់ដីធំៗក្នុងរយៈពេលមានទឹកជំនន់ ។ កំណើនចំណោត និង លក្ខណៈគ្មានជីវិតនៃច្រាំងទន្លេដែលផ្លាស់ប្តូរ នឹង ធ្វើឱ្យវាមានលក្ខណៈសមស្របសម្រាប់ការដាំដំណាំតាមមាត់ទន្លេតិចជាងកាលពីមុន ។* [EIA, ១៤៥]<br><br>*ច្រាំងទន្លេកាន់តែងាយបាក់ដីនិងហូរបាក់ច្រោះដីដោយសារការប្រែប្រួលកំពស់ទឹក ។ គេឃើញមានច្រាំងទន្លេចោតគ្មានរុក្ខជាតិនៅពេលនេះច្រើនជាងកាលពីពេលមុន ។ ចំណុចនេះគឺបណ្តាលមកពីការបាក់ច្រាំងទន្លេ ។* [EIA, ១៤០] |

| | |
|---|---|
| **ការហូរច្រោះដីអាងទឹក និង ទឹកល្អក់នៅខ្សែទឹកខាងក្រោម** | *ទីមួយ ជញ្ជាំងអាងទំនប់សឹករិចរិល ។ សារធាតុសឹកទាំងនេះភាគច្រើននឹងធ្លាក់ទៅកកនៅបាតអាងទឹក ប៉ុន្តែ ដីល្បប់និងដីផ្លដ្ឋិតឆ្នានឹងហូរចុះទៅខ្សែទឹកខាងក្រោម ដែលជាហេតុធ្វើឱ្យទឹកល្អក់ ។ ការហូរច្រោះដីនេះនឹងបង្កើតបញ្ហានៅខាងក្រោមខ្សែទឹក តែនៅក្នុងរយៈពេល ១០ ឆ្នាំដំបូងនៃប្រតិបត្តិការប៉ុណ្ណោះ ។*[EIA, ១៤៥] |
| **ទឹកល្អក់គឺមិនសមស្របសម្រាប់ការប្រើប្រាស់តាមផ្ទះ** | *ភាពល្អក់*[១] *គឺជាបញ្ហាមួយនៅក្នុងបណ្តាឆ្នាំដំបូងនៃការដំណើរការទំនប់យ៉ាលី អ្នកភូមិមិនអាចប្រើទឹកសម្រាប់ងូតឡើយ ។ ពេលនេះទឹកកំពុងចាប់ផ្តើមល្អក់ឡើងវិញទៀតហើយនៅក្នុងប្រទេសកម្ពុជា ដោយសារការងារសាងសង់ពាក់ព័ន្ធនឹងគម្រោងថ្មីៗទាំងឡាយនៅក្នុងប្រទេសវៀតណាម ។*[EIA, ១៣៩]<br><br>*នៅពេលមានទឹកជំនន់ ទឹកឡើងពណ៌ក្រហមនិងល្អក់ ... ជារឿយៗ មានក្លិនអាក្រក់ និង មានភក់ ... ។* [EIA, ១៤២] |
| **កំណើនហានិភ័យដឹកជញ្ជូន** | *ការធ្វើដំណើរដោយទូកកាន់តែមានគ្រោះថ្នាក់ដោយសារទឹកល្អក់ (ពិបាកមើលថ្មលិចទឹក) ។*[EIA, ១៤០] |
| **ការបាត់បង់ជម្រកត្រីដែលត្រូវបានផ្សារភ្ជាប់ទៅនឹងការហូរច្រោះដី/ដីល្បប់ដែលបណ្តាលមកពីទំនប់** | *គេគប្បីកត់សម្គាល់ថាទោះបីជាការប្រែប្រួលកំពស់ទឹកនៅប៉ែកកណ្តាលនិងប៉ែកខាងក្រោមនៃទន្លេសេសាននៅក្នុងប្រទេសកម្ពុជាមានលក្ខណៈទាបក្តី ក៏ការហូរច្រោះដីពីប៉ែកខាងលើនឹងត្រូវបានហូរចុះមកខ្សែទឹកខាងក្រោម និង នឹងធ្លាក់ចូលទៅក្នុងត្រពាំងជ្រៅនានានៅក្នុងរដូវប្រាំងដែរ ។ បន្តិចម្តងៗ ត្រពាំងជ្រៅទាំងនេះនឹងក្លាយទៅជារាក់ឡើងៗ ហើយលទ្ធភាពដ៏សំខាន់របស់វាក្នុងការបម្រើជាជម្រកត្រីនារដូវប្រាំងនឹងត្រូវថយចុះ ។* [EIA, ១៤៥] |

[១] **ភាពល្អក់**គឺជាការវាស់ភាពល្អក់កកររបស់ទឹកដែលបណ្តាលមកពីបរិមាណនៃសារធាតុកករនៅក្នុងទឹក ។ ភាពល្អក់មានផលប៉ះពាល់ជាអវិជ្ជមានលើគុណភាពទឹកផឹក និង នេសាទ ។

| | |
|---|---|
| **កំណើនសម្ពាធលើព្រៃឈើនៅតំបន់ខ្ពង់រាប** | *... ដីធ្វើដំណាំតាមមាត់ទន្លេត្រូវបាត់បង់ដោយសារទឹកជំនន់ និងការហូរច្រោះបាក់ដី ហើយសម្ពាធជម្រុញឱ្យរកដីដាំដំណាំបន្ថែមនៅតំបន់ខ្ពង់រាបឆ្ងាយពីទន្លេ បានកើនឡើង ។*[EIA, ១៨៦] |
| **ប្រព័ន្ធអេកូឡូស៊ីទន្លេត្រូវបានបន្ទុចបង្អាក់** | *ការប្រែប្រួលមិនទៀងទាត់នៅក្នុងទឹកទន្លេសេសាន បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសារពើរុក្ខជាតិ បក្សាបក្សី សត្វល្អូន និង វដ្តជលជីវិតផ្សេងៗតាមមាត់ទន្លេ ដែលពឹងអាស្រ័យលើចង្វាក់ធម្មជាតិនៃទន្លេនេះ ។* [EIA,១៣] |
| **ការប្តូរទីកន្លែងរបស់ត្រី (នៅក្នុងទន្លេសេសាន រវាងទន្លេសេសាននិងទន្លេមេគង្គ) ត្រូវបានបន្ទុចបង្អាក់** | *សម្រាប់ប្រភេទត្រីជាច្រើន គឺកំណើនលំហូរទឹកដំបូងនៅដើមរដូវវស្សានេះហើយដែលនាំឱ្យមានការប្តូរទីកន្លែង ។ លំហូរជម្រុញទាំងនេះ ជារឿយៗ ត្រូវបានពន្យារ និង ត្រូវបានកាត់បន្ថយនៅក្នុងទន្លេដែលមានការគ្រប់គ្រងជាមួយអាងទឹក ។ ទឹកភ្លៀងដំបូងនៃរដូវវស្សា ត្រូវបានប្រើសម្រាប់បំពេញអាងទឹក ... ។ ការបំពេញអាងទឹកអាចពន្យារពេលការឈានដល់ទំហំលំហូរនេះ [ដើម្បីធ្វើឱ្យទឹកធ្លាក់ធម្មជាតិអាចឆ្លងកាត់បាន] អស់រយៈពេលច្រើន ដែលជាហេតុធ្វើឱ្យត្រីមិនអាចទៅដល់គោលដៅរបស់វា ពោលគឺ កន្លែងពង ... ។ ការប្តូរទីកន្លែងដើម្បីពង ជារឿយៗ ត្រូវបានរារាំងដោយកង្វះលំហូរជម្រុញ ឬ ដោយលំហូរទឹករាក់ពេកក្នុងទូទាំងរដូវប្តូរទីកន្លែងសម្រាប់ឱ្យត្រីអាចទៅដល់កន្លែងពង ។*[EIA, ១៨៩] |
| **ហានិភ័យសុខភាពសាធារណៈ:**<br><br>**សារាយពុលដែលផ្សារភ្ជាប់ទៅនឹងអាងទឹកយ៉ាលី**<br>*ក្នុងរយៈពេល ២-៣ ឆ្នាំដំបូង (១៩៩៨-២០០០) ក្រោយបំពេញអាងទឹក [យ៉ាលី] ទំនងជាមានឧប្បត្តិហេតុជាមួយស្លែពុលពណ៌ខៀវ-បៃតងដែលបានបណ្តាលឱ្យមានបញ្ហាគុណភាពទឹកនៅក្នុងទន្លេសេសាននៅក្នុងខេត្តរតនៈគិរី ។*[EIA, ១៣៦] | |

*ទិន្នន័យអំពីគុណភាពទឹកនៅក្នុងការសិក្សានេះបានរកឃើញការប្រមូលផ្តុំនៃសារាយជាតិពុលនៅក្នុងអាងទឹកយ៉ាលី ។ ការសិក្សាបានបង្ហាញថាទឹកមានប្រភេទសារាយ* microcystis sp *ដែលគេដឹងថាផលិតជាតិពុលម្យ៉ាងហៅថា* microcystins *។ ផលប៉ះពាល់រយៈពេលវែងនៃជាតិពុល* microcystins *គឺថាវារារាំងការធ្វើដំណើរការថ្លើមបន្តិចម្តងៗ និង អាចបណ្តាលឱ្យស្លាប់បានបើគួបផ្សំជាមួយជម្ងឺថ្លើមផ្សេងទៀត ដូចជា រោគក្រិនថ្លើម (hepatitis) ជាដើម ។* [EIA, ១៣៥]

កំណត់សម្គាល់: កម្រិតនៃជាតិពុល microcystin នៅក្នុងទឹកទន្លេដែលបានពិសោធន៍មើលនៅភូមិភី និង វ៉ឺនសៃ កាលពីខែ ធ្នូ ឆ្នាំ ២០០៧ គឺស្ថិតនៅក្រោមកម្រិតរកឃើញ ។ ប៉ុន្តែ ការយកសំណាកមិនត្រូវបានធ្វើឡើងនៅក្នុងរយៈពេលមានហានិភ័យខ្ពស់នៅពេលដែលទឹកទន្លេស្ថិតនៅក្នុងហានិភ័យធំបំផុតនៃការធ្វើឱ្យកខ្វក់ ចាប់ពីខែមេសា ដល់ខែ ឧសភា ឡើយ ។ ការយកសំណាកនៅក្នុងរដូវប្រាំងគឺចាំបាច់ ។ [EIA, ១៣៥]

*ផ្អែកលើការវិភាគទឹកនិងសំណាកសារាយទាំងពីប្រទេសវៀតណាមនិងកម្ពុជា ក៏ដូចជាពីការធ្វើសម្ភាសន៍ដែរ សារាយនេះប្រហែលជាបានរីកលូតលាស់នៅក្នុងទន្លេខ្សែទឹកខាងក្រោមទំនប់យ៉ាលីដោយសារការបញ្ចេញទឹកបាតអាងដែលសម្បូណ៌សារធាតុចិញ្ចឹមពីអាងទឹកយ៉ាលី ។ គេឃើញមានសារាយវែងតូចពណ៌ខៀវ-បៃតងត្រូពិក/ពាក់កណ្តាលត្រូពិកពពួក Lyngbya （cf woolei） ដែលអាចផ្តល់រោគសញ្ញាដូចគ្នាដូចដែលបានរៀបរាប់ខាងលើ ។ ទឹកអាចមានជាតិពុល និង ធ្វើឱ្យរមាស់ ។ ការផឹកទឹកដែលមានរុក្ខជាតិនេះធ្វើឱ្យមានបញ្ហាផ្លូវដង្ហើម ឈឺក្បាល និង ឈឺក្រពះ ។ រុក្ខជាតិនេះអាចដុះទាំងនៅក្នុងអាងទឹកនិងទឹកទន្លេ និង លូតលាស់នៅក្នុងរយៈពេលមានពន្លឺថ្ងៃល្អ និង អាកាសធាតុក្តៅ ។ ផ្កាសារាយនេះអាចសម្លាប់ត្រី ។ នៅក្នុងអង្កេតនៅក្នុងខែ វិច្ឆិកា/ធ្នូ ឆ្នាំ ២០០៥ ជាតិពុលសារាយ ត្រូវបានរកឃើញនៅក្នុងអាងទឹកយ៉ាលី ប៉ុន្តែ មិនឃើញមាននៅក្នុងទន្លេខ្សែទឹកខាងក្រោមទេ ។*

**បញ្ហាដកដង្ហើមនិងមរណៈភាព**

*រោគសញ្ញាដែលបានរៀបរាប់ដោយប្រជាជនក្នុងមូលដ្ឋានក្រោយផឹកទឹកពីទន្លេសេសាន អាចបណ្តាលមកពីរុក្ខជាតិសារាយពណ៌ខៀវ-បៃតង ។ សារាយពណ៌ខៀវ-បៃតងនេះអាចផលិតជាតិពុលពីរប្រភេទ គឺជាតិពុលធ្វើឱ្យខូចថ្លើម (hepatotoxins) （វាយលុកថ្លើម） និង ជាតិពុលធ្វើឱ្យខូចសសៃប្រសាទ (neurotoxins) （វាយលុកប្រព័ន្ធសសៃប្រសាទ） ។ ជាតិពុលធ្វើឱ្យខូចសសៃប្រសាទអាចបណ្តាលឱ្យស្លាប់ប៉ុន្មាននាទីក្រោយពេលលេបចូលក្នុងពោះ រីឯ ជាតិពុលធ្វើឱ្យខូចថ្លើមច្រើនចំណាយពេលរាប់ម៉ោងដល់រាប់ថ្ងៃមុនពេលមរណៈភាពកើតឡើង ។ ក្នុងករណីទាំងពីរ នេះ បញ្ហាដកដង្ហើមគឺជាមូលហេតុផ្ទាល់ច្រើនបំផុតនៃការស្លាប់ ។* [EIA, ១៣៥]

*រោគរមាស់ពីការងូតទឹកនិងហែលទឹកនៅក្នុងទន្លេសេសានអាចកើតមកពីសារាយមួយចំនួន។ ប្រភេទមានច្រើនជាងគេគឺសារាយពណ៌ខៀវ-បៃតង* Cyanophycea *និង* Chrysophycea *។ សារាយទាំងនេះមានថង់ដែលផ្ទុកវត្ថុរាវធ្វើឱ្យរមាស់ដែលបែកធ្លាយពេលប៉ះវា។*[EIA, ១៣៥]

**បញ្ហាសារាយពុលរំពឹងថាមាននៅក្នុងអាងទឹកថ្មី**

*... នៅក្នុងរយៈពេលពី ៥ ទៅ ១០ ឆ្នាំដំបូងនៅពេលដែលសារធាតុចិញ្ចឹមត្រូវបានបញ្ចេញពីសម្រាមសរីរាង្គរលួយពីផ្ទៃដីលិចទឹក ទឹកក្នុងអាងទាំងនេះអាចកាន់តែអស់អុកស៊ីហ្សែន និង អាចមានបញ្ហាសារាយពណ៌ខៀវ-បៃតង តាមរដូវ។ បញ្ហានេះទំនងជាច្រើនកើតឡើងនៅដំណាច់រដូវលំហូរទឹកទាប (ខែ មេសា-ឧសភា)។*

*[ទំនប់] នាអនាគតនឹងធ្វើឱ្យលិចទឹកផ្ទៃដីថ្មី និង បង្កើតទឹកសម្បូណ៌សារធាតុចិញ្ចឹមនៅក្នុងទន្លេខ្សែទឹកខាងក្រោមក្នុងរយៈពេលពី ៥-១០ ឆ្នាំ ក្រោយមានការគ្រប់គ្រងទឹក។ ប្រការនេះអាចបង្កើតបញ្ហាសារាយថ្មី។* [EIA, ១៤៨]

*អាងទឹកថ្មីដែលកំពុងសាងសង់អាចនាំឱ្យមានរយៈពេលថ្មីមួយនៃទឹកសម្បូណ៌សារធាតុចិញ្ចឹមដែលអាចជម្រុញឱ្យមានការប្រមូលផ្តុំសារាយដែលបង្កបញ្ហា ... ផលប៉ះពាល់ដូចគ្នាអាចកើតមានឡើងជាថ្មីទៀតដោយសារទំនប់ថ្មីនានាដែលគេកំពុងសាងសង់។*[EIA, ១៣៨]

**៣: ការពិនិត្យឡើងវិញនូវអនុសាសន៍ EIA ស្តីពីការកាត់បន្ថយផលប៉ះពាល់ខាងក្រោមខ្សែទឹក និង ការផ្តល់សំណង**

| **អនុសាសន៍វិធានការកាត់បន្ថយផលប៉ះពាល់** | **សេចក្តីអធិប្បាយអំពី EIA** |
|---|---|
| **១. អាងគ្រប់គ្រងទឹកនៃទំនប់សេសាន ៤A (ព្រំដែនវៀតណាម-កម្ពុជា)** | *វិធានការនេះនឹងធ្វើឱ្យមានស្ថេរភាពដល់ការប្រែប្រួលលំហូរទឹករាល់ថ្ងៃ និង គឺជាវិធានការបន្ថយផលប៉ះពាល់ដ៏សំខាន់បំផុតសម្រាប់កិច្ចអភិវឌ្ឍន៍មានស្រាប់និងអនាគត។ លំហូរទឹកចេញពីអាងនៃ* |

| | |
|---|---|
| | *ទំនប់សេសាន ៤A គប្បីមានលក្ខណៈស្មើគ្នានឹងលំហូរធម្មជាតិតាមដែលអាចធ្វើទៅបាន ។*[EIA, ១៥]<br><br>*ការប្រែប្រួលប្រចាំថ្ងៃនឹងត្រូវបានកាត់បន្ថយនៅពេលដែលអាងគ្រប់គ្រងទឹកនៃទំនប់សេសាន ៤A ដំណើរការ ។*[EIA, ៧០] **(សូមមើលយោបល់ចុងក្រោយ)** |
| **២. ការកែប្រែប្រតិបត្តិការដើម្បីកាត់បន្ថយការប្រែប្រួលទឹក/ការហូរច្រោះបាក់ដីខាងក្រោមខ្សែទឹក និង ដើម្បីកែលម្អស្ថានភាពទន្លេជារួម** | របាយការណ៍ EIA ផ្តល់ជាអនុសាសន៍នូវវិធានប្រតិបត្តិការមួយចំនួនសម្រាប់ទួរប៊ីននិងច្រកបញ្ចេញទឹកដើម្បីកាត់បន្ថយការប្រែប្រួលកំពស់ទឹក ... និង *ជាទូទៅ ដើម្បីធ្វើតាមគម្រូលំហូរធម្មជាតិ ។*[EIA, ៦០]<br><br>ជាផ្នែកមួយនៃសម្បទាន [ប្រតិបត្តិការ] របស់ខ្លួន ក្រុមហ៊ុនអគ្គិសនីនៅប្រទេសណ័រវ៉េសនិងអឺរ៉ុបមានកាតព្វកិច្ចត្រូវបញ្ចេញទឹកជំនន់ជម្រុញសម្រាប់ត្រីផ្លាស់ទីកន្លែង (ដូចជាត្រីសាលម៉ុង និង ត្រី trout) ។ [EIA, ១៤៩] |
| **៣. ឃ្លាំមើលផលប៉ះពាល់នៃប្រតិបត្តិការលើបរិមាណនិងគុណភាពទឹកខាងក្រោមខ្សែទឹក**<br><br><br><br><br><br><br>**ការបញ្ចេញទឹកប្រសើរបំផុត** | *ការយកចិត្តទុកដាក់ពិសេសលើប្រតិបត្តិការក្នុងបណ្តាឆ្នាំដំបូង គប្បីផ្តោតលើផលប៉ះពាល់នៃការបញ្ចេញទឹកជាអប្បបរមា និង របបប្រតិបត្តិការនៃរោងចក្រវារីអគ្គិសនី ពោលគឺ ផលប៉ះពាល់នៃផលិតកម្មខ្ពស់បំផុតលើជលជីវិតនៅខាងក្រោមខ្សែទឹក ។ ជាពិសេសការវាយតម្លៃគឺចាំបាច់ត្រូវធ្វើលើការបញ្ចេញទឹកអប្បបរមា និងភាពគ្រប់គ្រាន់ដើម្បីរក្សាទីជម្រកជលជាតិ និង ពូជត្រី ។* [EIA, ១៨១]<br><br>របាយការណ៍ EIA ផ្តល់ជាអនុសាសន៍នូវការឃ្លាំមើលដើម្បី "កំណត់យុទ្ធសាស្រ្តបញ្ចេញទឹកអប្បបរមាប្រសើរបំផុត" ដើម្បីរក្សាកំពស់ទឹកដែលអាចទ្រទ្រង់ជីវិតជលជាតិ សត្វព្រៃនិងរុក្ខជាតិព្រៃ និងសារពើរុក្ខជាតិមាត់ទឹក ។ [EIA, ១៨១] |

| | |
|---|---|
| **៤. ឃ្លាំមើលគុណភាពទឹក** | *ទឹកគប្បីត្រូវបានឃ្លាំមើលដើម្បីរកមើលសារធាតុចិញ្ចឹម សមាសភាពប្រភេទសារាយនិងជាតិពុលសារាយ សម្រាប់រយៈពេលពីរបីឆ្នាំក្រោយ ពេលដែលទំនប់ដំណើរការ ។*[EIA, ១៤៨]<br><br>*សំណាកទឹកគប្បីត្រូវយករាល់ខែ ។ ការយកសំណាកគុណភាពទឹកនៅក្នុងប្រទេសកម្ពុជាអាចធ្វើដោយបុគ្គលិកក្រសួងធនធានទឹក និង ឧតុនិយមនៅបានលុង និង បញ្ជូនតាមយន្តហោះទៅភ្នំពេញដើម្បីធ្វើការវិភាគ ។ ការយកសំណាកទឹកនៅក្នុងប្រទេសវៀតណាមអាចធ្វើដោយបុគ្គលិកនៅក្នុងរោងចក្រវារីអគ្គិសនីយ៉ាលី ហើយសំណាកអាចផ្ញើទៅក្រុងហូជីមិញ ដាណាំង ឬ ហាណូយ ដើម្បីធ្វើការវិភាគ ។* |
| **យុទ្ធនាការឃ្លាំមើលសារាយ/យុទ្ធនាការព័ត៌មានអំពីសារាយ ដើម្បីផ្សព្វផ្សាយជូនសាធារណជនអំពីហានិភ័យសុខភាព** | *កម្មវិធីឃ្លាំមើលសារាយមួយគប្បីត្រូវបានបង្កើតឡើង ដែលអាចរកឃើញបញ្ហាណាមួយ ក៏ដូចជាយុទ្ធនាការផ្សព្វផ្សាយព័ត៌មានមួយដែលជូនដំណឹងដល់ប្រជាជនអំពីគ្រោះថ្នាក់នៃការផឹកទឹកដែលមានជាតិសារាយច្រើន ។ ផ្ការីកមួយនៃសារាយពុលអាចលូតលាស់ក្នុងរយៈពេល ២-៣ ថ្ងៃ ហើយប្រព័ន្ធជូនដំណឹងមួយគប្បីត្រូវបានបង្កើតឡើង ។[EIA, ១៤៨]* |
| **៥. សំណើវិធានការសំខាន់ៗចំនួន ៥ ដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារប្រតិបត្តិការទំនប់** | *វិធានការសំខាន់ៗទាំងឡាយដើម្បីកាត់បន្ថយផលប៉ះពាល់ពីគម្រោងវារីអគ្គិសនីយ៉ាលី និង ពីប្រតិបត្តិការនៃការអភិវឌ្ឍន៍វារីអគ្គិសនីនាអនាគតនៅក្នុងទន្លេសេសាន រួមមាន:*<br>*(១) បង្កើតទំនប់សេសាន ៤A ជាអាងគ្រប់គ្រងទឹកមួយ ។*<br>*(២) បង្កើតប្រព័ន្ធជូនដំណឹងជាមុនសម្រាប់ការបញ្ចេញទឹក និង លំហូរទឹកភ្លាមៗ ។*<br>*(៣) ពន្យារពេលបំពេញទឹកអាងក្នុងរដូវវស្សាឱ្យបានយូរ ។*<br>*(៤) បន្ថយធាតុចូលចិញ្ចឹមសរីរាង្គទៅក្នុងទន្លេនិងអាងទឹក ។*<br>*(៥) ពិចារណាបង្កើតកម្មវិធីចិញ្ចឹមត្រី និង អភិវឌ្ឍកម្មវិធីមួយសម្រាប់ផលកសិកម្ម ។*[EIA, ១៥] |

**៦. អនុសាសន៍របាយការណ៍ EIA សម្រាប់ "សំណងសង្គម"**

របាយការណ៍ EIA ផ្ដល់អនុសាសន៍ចំនួនប្រាំពីរដើម្បីកាត់បន្ថយផលប៉ះពាល់លើជីវភាពរស់នៅ សន្តិសុខស្បៀង កម្រិតជីវភាព និង សុខុមាលភាពទូទៅនៅខាងក្រោមខ្សែទឹក ក្នុងកម្រិតសហគមន៍និងគ្រួសារ។ អ្នកពិគ្រោះការងារជឿថា "ជម្រើសសម្រាប់ផ្ដល់សំណងសង្គម" ទាំងនេះ គឺគួរឱ្យចង់បានក្នុងរយៈពេលវែងជាង "ការសងប្រាក់ តែមួយលើក។"

អនុសាសន៍ដំបូងទាំងបួនគឺសំដៅ "ផ្ដល់សំណងសម្រាប់ការបាត់បង់ស្បៀងអាហារ បសុសត្វ ដីធ្លី និង ប្រាក់ចំណូលៈ"

១) បង្កើតកម្មវិធីជលកសិកម្មមួយ

២) អភិវឌ្ឍជម្រើសផ្សេងៗនៅក្នុងការចិញ្ចឹមសត្វ និង/ឬ កម្មវិធីចិញ្ចឹមមាន់ទា

(៣) អភិវឌ្ឍជម្រើសផ្សេងៗសម្រាប់ការគ្រប់គ្រងដំណាំ និង គំនិតផ្ដួចផ្ដើមដំណាំបន្ទាប់បន្សំ និង

(៤) ចាប់ផ្ដើមនិងលើកស្ទួយការគ្រប់គ្រងព្រៃឈើផ្អែកលើសហគមន៍ ឬ កម្មវិធីព្រៃឈើសង្គម។

អនុសាសន៍ទី ៥ ដល់ ៧ "នឹងលើកស្ទួយកម្រិតជីវភាព និង សុខុមាលភាពទូទៅ ដែលរួមចំណែកដោយផ្ទាល់និងដោយប្រយោលដល់ការកែលម្អសុខភាពៈ"

(៥) ចាប់ផ្ដើមផ្ដល់អគ្គិសនី

(៦) បង្កើតប្រព័ន្ធទឹកផឹកនិងប្រព័ន្ធអនាម័យ

(៧) កែលម្អប្រព័ន្ធថែទាំសុខភាព។

**៧. ការពិគ្រោះយោបល់សាធារណៈ**

អនុសាសន៍សម្រាប់ឱ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងតំបន់ខាងក្រោមខ្សែទឹកទន្លេសេសាន -*ក្រុមប្រជាជនខាងក្រោមនេះគប្បីបានចូលរួមក្នុងដំណើរការពិគ្រោះយោបល់ភាគីពាក់ព័ន្ធ។* [EIA, ១៦]

(១) ប្រជាជនរងផលប៉ះពាល់ដោយផ្ទាល់ដែលរស់នៅក្នុងភូមិជាប់ទន្លេ

(២) ប្រជាជនរងផលប៉ះពាល់ដោយផ្ទាល់ដែលរស់នៅក្នុងតំបន់ជាប់គ្នា

(៣) ប្រជាជនដែលប្រើទន្លេនេះសម្រាប់សកម្មភាពជីវភាពរស់នៅនានា ប៉ុន្តែ មិនរស់នៅតាមដងទន្លេទេ

(៤) ស្ត្រីនៅក្នុងភូមិនានាដែលរងផលប៉ះពាល់ដោយផ្ទាល់

(៥) អង្គការប្រជាជន

(៦) បុគ្គលិកសុខាភិបាល និង គ្រូថ្នាំខ្មែរ

(៧) ប្រធានភូមិនិងប្រធានឃុំនៃតំបន់ដែលរងផលប៉ះពាល់ដោយផ្ទាល់

(៨) តំណាងរដ្ឋបាលស្រុក

(៩) តំណាងរដ្ឋបាលខេត្ត

(១០) អង្គការមិនមែនរដ្ឋាភិបាលដែលបំពេញការងារនៅតាមតំបន់រងផលប៉ះពាល់ ។

***ដំណើរការពិគ្រោះយោបល់ភាគីពាក់ព័ន្ធគប្បីនាំឱ្យមានវិធានការនានាសម្រាប់កាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៅតាមដងទន្លេសេសាននៅក្នុងប្រទេសកម្ពុជាដែលបណ្តាលមកពីការអភិវឌ្ឍន៍វារីអគ្គិសនីនៅក្នុងប្រទេសវៀតណាម ។***

***ការធ្វើផែនការនិងការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ គប្បីត្រូវធ្វើឡើងក្នុងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នមានស្រាប់ និង ដោយគាំទ្រស្ថាប័នទាំងនេះ ដូចជាក្រុមប្រឹក្សាឃុំ និង មណ្ឌលសុខភាពស្រុកជាដើម ។***

***អង្គការប្រជាជន និង អង្គការមិនមែនរដ្ឋាភិបាលដែលបំពេញការងារនៅក្នុងតំបន់ទាំងនេះ គប្បីចូលរួមក្នុងសកម្មភាពកាត់បន្ថយផលប៉ះពាល់ផងដែរ ។***

## ៨. អនុវត្តការឃ្លាំមើល

"អង្គភាពបរិស្ថាននិងសហគមន៍" គប្បីមានមន្ត្រីឃ្លាំមើលបរិស្ថានដែលទទួលបន្ទុក*ពិនិត្យមើលការងារកាត់បន្ថយផលប៉ះពាល់ទាំងអស់ និង ឃ្លាំមើលយ៉ាងទៀងទាត់នូវផលប៉ះពាល់របស់គម្រោងដោយប្រៀបធៀបនឹងសូចនាករនិងបទដ្ឋានមួយចំនួន ។ ការឃ្លាំមើលជាបីកម្រិតត្រូវបានស្នើឡើង: ការឃ្លាំមើលដ៏ទៀងទាត់ ការពិនិត្យមើលឡើងវិញប្រចាំឆ្នាំ និង ការពិនិត្យមើលឡើងវិញបណ្តោះអាសន្ន ។*

*នៅក្នុងអំឡុងពេលសាងសង់ អង្គភាពបរិស្ថាននិងសហគមន៍នឹងធ្វើការឃ្លាំមើលដ៏ទៀងទាត់ រាយការណ៍ជូនអ្នកគ្រប់គ្រងគម្រោងរៀងរាល់សប្តាហ៍ និង រាយការណ៍ភ្លាមៗនៅពេលដែលបញ្ហាដោយឡែកណាមួយកើតឡើង ។* ចំណុចនេះរួមមានការឃ្លាំមើលអ្នកម៉ៅការ *ក៏ដូចជាការកាត់បន្ថយផលប៉ះពាល់ និង សកម្មភាពផ្សេងទៀតរបស់គម្រោងផងដែរ ។ របាយការណ៍វឌ្ឍនភាពប្រចាំខែ និង របាយការណ៍ប្រចាំឆ្នាំ គប្បីត្រូវផ្ញើជូនអាជ្ញាធរពាក់ព័ន្ធនានានៅក្នុងប្រទេសកម្ពុជា និង វៀតណាម ។*[EIA, ១៨១]

*ការទទួលខុសត្រូវលើការឃ្លាំមើលគឺស្ថិតនៅជាមួយម្ចាស់គម្រោង (អគ្គិសនីវៀតណាម) ប៉ុន្តែ គប្បីត្រូវបាន ពិភាក្សាជាមួយនិងបញ្ជាក់អះអាងដោយអាជ្ញាធរកម្ពុជា និង វៀតណាម ។*

*ការប្រមូលទិន្នន័យជលវិទ្យានិងទិន្នន័យអំពីកករ - ម្ចាស់គម្រោងទទួលបន្ទុកផ្តល់មូលនិធិសមស្របជូនដល់ការ សិក្សាទាំងអស់ដែលគេយល់ឃើញថាចាំបាច់ ។[EIA, ១៨២]*

*ម្ចាស់គម្រោងទទួលបន្ទុកបង្កើតនិងអនុវត្តកម្មវិធីឃ្លាំមើលដ៏ពេញលេញមួយ ដែលត្រូវទទួលការឯកភាពពី អាជ្ញាធរកម្ពុជានិងវៀតណាមដែលពាក់ព័ន្ធ ។ ម្ចាស់គម្រោងគប្បីផ្តល់មូលនិធិជូនគ្រប់សកម្មភាពទាំងអស់នៅក្នុង កម្មវិធីដែលបានឯកភាពនេះ ។*

*ការឃ្លាំមើលដំណាក់កាលធ្វើប្រតិបត្តិការ – ម្ចាស់គម្រោងទទួលបន្ទុកទាំងស្រុងលើការផ្តល់មូលនិធិនិងការ អនុវត្តកម្មវិធីឃ្លាំមើល និង គប្បីត្រូវរៀបចំតាមរយៈការពិភាក្សាជាមួយអាជ្ញាធរសមស្របនៅក្នុងប្រទេស កម្ពុជា និង វៀតណាម ។*

## ៥: យោបល់ចុងក្រោយ

### ៥.១ ជំហានខាងមុខ - អាទិភាព និង ការធ្វើសេចក្តីសម្រេចចិត្តលើការកាត់បន្ថយផលប៉ះពាល់ និង ការផ្តល់ សំណង

- យោងតាមកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ ដែលចុះហត្ថលេខាដោយប្រទេសថៃឡង់ដ៏ សាធារណ រដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កម្ពុជា និង វៀតណាម រដ្ឋជាប់ទន្លេមេគង្គទាំងឡាយមានកាតព្វកិច្ច ត្រូវ "**ខិតខំជៀសវាង និង កាត់បន្ថយផលប៉ះពាល់ពោរពេញដោយអន្តរាយ** ដែលអាចកើតឡើងចំពោះ បរិស្ថាន ជាពិសេសបរិមាណនិងគុណភាពទឹក ស្ថានភាពជលជាតិ (ប្រព័ន្ធអេកូឡូស៊ី) និង តុល្យភាព បរិស្ថាននៃប្រព័ន្ធទន្លេ **ចាប់តាំងពីការអភិវឌ្ឍន៍និងការប្រើប្រាស់ធនធានអាងទន្លេមេគង្គ ។**" នៅក្នុង បរិបទនេះ អនុសាសន៍ EIA ទាំងអស់សម្រាប់កាត់បន្ថយផលប៉ះពាល់ ការពិគ្រោះយោបល់ ការអនុវត្ត និង ការទទួលបន្ទុកលើការផ្តល់មូលនិធិ គប្បីត្រូវបានពិនិត្យឡើងវិញយ៉ាងប្រុងប្រយ័ត្នជាមួយភាគី ពាក់ព័ន្ធកម្ពុជា ដើម្បីកំណត់អាទិភាពសម្រាប់ការធ្វើវិនិយោគ និង ការធ្វើសកម្មភាព ។

- ផលប៉ះពាល់ខាងក្រោមខ្សែទឹកខ្លះ ជាក់ស្តែង ការគម្រាមកំហែងរបស់ការបំពុលនៃសារាយពុលនៅក្នុងរដូវប្រាំង និង ទឹកជំនន់ធ្ងន់ធ្ងរដែលបង្ខំឱ្យមានការផ្លាស់លំនៅដ្ឋានរបស់សហគមន៍នៅតាមដងទន្លេ តាមទស្សនៈរបស់យើង គប្បីបើកឱ្យមានការអនុវត្តមាត្រា ១០ នៃកិច្ចព្រមព្រៀងទន្លេមេគង្គដែលចែងពីស្ថានភាពគ្រោះអាសន្ន។ មាត្រា ១០ ចែងថា: *នៅពេលណាដែលភាគីមួយដឹងអំពីបញ្ហាពិសេសនៃបរិមាណឬគុណភាពទឹកដែលគឺជាគ្រោះអាសន្នដែលតម្រូវឱ្យមានការឆ្លើយតបជាបន្ទាន់ ភាគីនោះត្រូវផ្តល់ដំណឹងនិងពិគ្រោះដោយផ្ទាល់ជាមួយភាគីពាក់ព័ន្ធ និង គណៈកម្មាធិការចម្រុះរបស់គណៈកម្មការទន្លេមេគង្គ ដោយមិនបង្អែបង្អង់ ដើម្បីចាត់វិធានការកែតម្រូវសមស្រប ។*

## ៥.២ បញ្ហាបន្ទាន់

ផ្អែកលើទស្សនៈរបស់យើងអំពីរបាយការណ៍ EIA និង សេចក្តីថ្លែងការណ៍ថ្មីៗពីសហគមន៍រងផលប៉ះពាល់នានានៅភូមិភាគឦសានប្រទេសកម្ពុជា (សូមមើលឧបសម្ព័ន្ធ ១) យើងបានកំណត់បញ្ហាបន្ទាន់ដូចខាងក្រោមនេះ:

- **ការគម្រាមកំហែងសុខភាពសាធារណៈដោយសារហានិភ័យនៃការផ្ទុះរាលដាលនៃសារាយពុលនៅក្នុងអាងទើបបំពេញទឹករបស់វៀតណាមដែលធ្វើឱ្យកខ្វក់ទឹកនៅខាងក្រោមខ្សែទឹក។** ដំណោះស្រាយបន្ទាន់ និងដំណោះស្រាយរយៈពេលវែងចំពោះបញ្ហាគុណភាពទឹករបស់កម្ពុជាដែលបណ្តាលមកពីទំនប់និងអាងទឹករបស់អគ្គិសនីវៀតណាម គឺចាំបាច់។ ឧទាហរណ៍ ដំណោះស្រាយនេះអាចរួមមានការផ្គត់ទឹកផឹកប្រកបដោយសុវត្ថិភាពដែលត្រូវផ្តល់ជូនដល់សហគមន៍មានហានិភ័យនានានៅតាមដងទន្លេសេសាន នៅក្នុងរដូវប្រាំង និង វិនិយោគលើប្រព័ន្ធច្រោះទឹក និង អណ្តូងទឹកនៅតាមសហគមន៍មានហានិភ័យ ។

- **ជំនួយទឹកជំនន់/ជំនួយផ្លាស់លំនៅដ្ឋានសម្រាប់គ្រួសារទាំងឡាយដែលប្តូរទីលំនៅទៅតំបន់ខ្ពង់រាបដើម្បីគេចចេញពីទឹកជំនន់យូរ និង ការខូចខាតដោយទឹកជំនន់ដែលត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរថែមទៀតដោយប្រតិបត្តិការទំនប់នៅខាងលើខ្សែទឹកក្នុងរដូវវស្សា។** ស្ថាប័នរដ្ឋាភិបាលក្នុងមូលដ្ឋាន សហគមន៍រងផលប៉ះពាល់ និង អង្គការអភិវឌ្ឍន៍មិនមែនរដ្ឋាភិបាល គប្បីវាយតម្លៃតម្រូវការជាបន្ទាន់ និង ស្នើសុំជំនួយហិរញ្ញវត្ថុពីម្ចាស់គម្រោង ពោលគឺអគ្គិសនីវៀតណាម តាមរយៈគណៈកម្មាធិការទន្លេសេសាន គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និង លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនៅក្រុងវៀងច័ន្ទ ដែលត្រូវបានផ្តល់មូលនិធិដោយអ្នកផ្តល់ជំនួយ។ (សូមមើលមាត្រា ១០ នៃកិច្ចព្រមព្រៀងទន្លេមេគង្គ) ។

- **កាត់បន្ថយការប្រែប្រួលទឹកប្រចាំថ្ងៃ និង ការបញ្ចេញទឹកធ្វើឱ្យអន្តរាយផ្សេងទៀតពីទំនប់និងអាងទឹកនៅខ្សែទឹកខាងលើ។** របាយការណ៍ EIA លើកឡើងថា *"ការប្រែប្រួលប្រចាំថ្ងៃនៅក្នុងលំហូរទឹកទន្លេពីគម្រោងវារីអគ្គិសនីយ៉ាលីមានផលប៉ះពាល់ធំបំផុត [នៅខាងក្រោមខ្សែទឹក] ហើយផលប៉ះពាល់ទាំងនេះនឹងមិនបញ្ឈប់ទេប្រសិនបើមិនមានចាត់វិធានការកាត់បន្ថយឱ្យបានសមស្រប។"* [EIA, ១៨៧] ទំនប់សេសាន ៤A ត្រូវបានបង្ហាញថាជា "អាងគ្រប់គ្រងទឹក"មួយដែលនឹងកាត់បន្ថយប្រកបដោយប្រសិទ្ធភាពនូវការប្រែប្រួលទឹកធ្វើឱ្យអន្តរាយប្រចាំថ្ងៃដែលបណ្តាលមកពីប្រតិបត្តិការទំនប់នៅខ្សែទឹកខាងលើជាស្ថានីយអគ្គិសនីកំពូល។ របាយការណ៍ EIA រាយការណ៍ថាទំនប់សេសាន ៤A នេះត្រូវបញ្ចប់ជាស្ថាពរនៅក្នុងខែ សីហា ឆ្នាំ ២០០៧ តាមការលើកឡើងដោយម្ចាស់គម្រោង ពោលគឺ អគ្គិសនីវៀតណាម។ តាមពិត ទំនប់សេសាន ៤A នឹងមិនទាន់បញ្ចប់ជាស្ថាពរទេរហូតដល់រយៈពេលបីឆ្នាំទៀត និងនឹងត្រូវបានដំណើរការដើម្បីផលិតអគ្គិសនី ពោលគឺមិនមែនសម្រាប់គ្រប់គ្រងលំហូរទឹកទន្លេទេ។ យោងតាម *ទីភ្នាក់ងារសារព័ត៌មានវៀតណាម* (Vietnam News Agency) (ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៨) គម្រោងទំនប់សេសាន ៤A នឹងមានទួប៊ីនបីសម្រាប់សមត្ថភាពតម្លើងបង្កើតថាមពល ៦៣ មេហ្គាវ៉ាត់ និង នឹងត្រូវបានបញ្ចប់ជាស្ថាពរនៅមុនដំណាច់ខែ កក្កដា ឆ្នាំ ២០១០។ (ធនាគារវៀតណាមសម្រាប់វិនិយោគនិងអភិវឌ្ឍន៍ និង ក្រុមហ៊ុនចម្រុះវៀតណាម-រុស្ស៊ីមួយ កំពុងផ្តល់មូលធនវិនិយោគចំនួន ៧៥ លានដុល្លារ។) អ្វីដែលការប្រកាសព័ត៌មាននេះលើកឡើងសម្រាប់ប្រជាជនកម្ពុជានៅខាងក្រោមខ្សែទឹក គឺថាការប្រែប្រួលធ្វើឱ្យអន្តរាយនៅក្នុងលំហូរទឹកទន្លេនឹងបន្តទៅទៀតមិនមានថយចុះទេ - លុះត្រាណាតែអគ្គិសនី វៀតណាមត្រូវបានបញ្ជាឱ្យកែតម្រូវប្រតិបត្តិការរបស់ខ្លួនឱ្យបានសមស្រប។

ដើម្បីផ្តល់ព័ត៌មានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តស្តីពីការកែប្រែប្រតិបត្តិការដែលអាចកាត់បន្ថយឬសម្រាលផលប៉ះពាល់ខាងក្រោមខ្សែទឹក **ស្ថានភាពប្រតិបត្តិការមួយកញ្ចប់ដ៏ពេញលេញសម្រាប់ធ្វើឱ្យគោលដៅផលិតអគ្គិសនីនៅខាងលើខ្សែទឹកមានតុល្យភាពជាមួយនឹងភាពចាំបាច់នៃការស្តារនិងរក្សាស្ថានភាពលំហូរទឹកធម្មជាតិនៅខាងក្រោមខ្សែទឹក គប្បីត្រូវបានវាយតម្លៃមើលជាបន្ទាន់។ ការប្តូរពីប្រតិបត្តិការខ្ពស់បំផុតទៅជាប្រតិបត្តិការតាមតម្រូវការអគ្គិសនីជាមធ្យមវិញនៅតាមគ្រប់ទំនប់នៅខាងលើខ្សែទឹកទាំងអស់ឬទំនប់ណាមួយ គប្បីត្រូវបានពិចារណាជាជម្រើសមួយ ដោយផ្អែកលើការអនុវត្តប្រសើរបំផុតដែលអភិវឌ្ឍដោយក្រុមហ៊ុនអគ្គិសនីធំៗនៅកន្លែងផ្សេង។** ការផ្តល់មូលនិធិ និង ជំនួយបច្ចេកទេសសម្រាប់គំនិតផ្តួចផ្តើមនេះ អាចត្រូវបានផ្តល់តាមរយៈគណៈកម្មការទន្លេមេគង្គដែលទទួលមូលនិធិពីអ្នកផ្តល់ជំនួយ និង ម្ចាស់គម្រោង ពោលគឺ អគ្គិសនីវៀតណាម។

**៥.៣ គោលនយោបាយ និង ដំណើរការនៃស្ថានីយវារីអគ្គិសនីនៅលើដៃទន្លេមេគង្គឆ្លងកាត់ព្រំដែន គប្បីត្រូវបាន ពិនិត្យឡើងវិញ។**

ចំពោះមុខផលប៉ះពាល់ឆ្លងព្រំដែននិងធ្វើឱ្យអន្តរាយមិនអាចប្រកែកបាននៃទំនប់វារីអគ្គិសនីលើទន្លេសេសាន គួបផ្សំជាមួយនឹងកង្វះខាតក្របខ័ណ្ឌនិយ័តកម្មនិងក្របខ័ណ្ឌច្បាប់ដើម្បីធ្វើឱ្យគោលដៅផលិតអគ្គិសនីមានតុល្យភាពជាមួយនឹងអាទិភាពផ្សេងទៀតតាមដងទន្លេ គោលនយោបាយនិងការដំណើរការរោងចក្រវារីអគ្គិសនីដល់កម្រិតកំពូលនៅលើដៃទន្លេឆ្លងព្រំដែននៃទន្លេមេគង្គគប្បីត្រូវបានពិនិត្យឡើងវិញ និង គប្បីត្រូវបានពិចារណានៅក្នុងបរិបទនៃការអនុវត្តពិភពលោកប្រសើរបំផុត និង ការទទួលខុសត្រូវរបស់រដ្ឋស្របតាមកិច្ចព្រមព្រៀងឆ្នាំ ១៩៩៥ របស់គណៈកម្មការទន្លេមេគង្គ ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅក្នុងតំបន់អាងទន្លេមេគង្គ។

**ចប់/ការពិនិត្យឡើងវិញនូវរបាយការណ៍ EIA ទន្លេសេសាន**
**ខែ កុម្ភៈ ឆ្នាំ ២០០៨**

## ឧបសម្ព័ន្ធ ១: ព័ត៌មានបច្ចុប្បន្នភាពអំពីទន្លេសេសាន - ខែ តុលា - ធ្នូ ឆ្នាំ ២០០៧

## រូបថត និង ការបកប្រែដោយបណ្តាញការពារទន្លេ 3S ខេត្តរតនះគីរី




| ១. សេចក្តីថ្លែងការណ៍នានាអំពីអ្នកដឹកនាំសហគមន៍ដែលរងផលប៉ះពាល់ពីទំនប់ | |
|---|---|
| លោក ជា ពុតទី<br>អភិបាលរង ស្រុកតាវែង<br>ទន្លេសេសាន<br>(រូបថតខាងលើ) | "យើងត្រូវការយុទ្ធសាស្ត្រល្អមួយដើម្បីរៀបចំផែនការសម្រាប់ជំហានខាងមុខ ។ យើងដឹងថាវៀតណាមបានសាងសង់ទំនប់ និង បានប៉ះពាល់សហគមន៍នានានៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែ ពេលនេះយើងត្រូវតែពិភាក្សាគ្នា និង មានសាមគ្គីភាពល្អ និង ផ្តល់យោបល់ជូនដល់មេដឹកនាំរដ្ឋាភិបាល ។<br><br>ខ្ញុំមិនមានអំណាចច្រើនទេ ។ របៀបរស់នៅរបស់ខ្ញុំគឺដូចគ្នានឹងសហគមន៍ទាំងឡាយនៅទីនេះអញ្ចឹងដែរ ។ ខ្ញុំបានទៅចូលរួមសិក្ខាសាលាស្តីពី EIA ទន្លេសេសាននៅភ្នំពេញ និង បានផ្តល់យោបល់ជាច្រើន ។ តំណាងមួយរូបមកពីគណៈកម្មការទន្លេមេគង្គក៏បានចូលស្តាប់រួមផងដែរ ។ ខ្ញុំបានលើកបញ្ហា និង អ្វីដែលសហគមន៍ចង់បានដើម្បីជាដំណោះស្រាយ ។ ប្រសិនបើរដ្ឋាភិបាលវៀតណាមមិនអាចរកដំណោះស្រាយជូនសហគមន៍បានទេ និង បន្តសាងសង់ទំនប់ នោះពួកគេគប្បីកសាងផ្លូវថ្នល់និងខ្សែបញ្ជូនអគ្គិសនីដើម្បីផ្តល់ជូនសហគមន៍ ។ ពួកគេក៏គប្បីសង់ផងដែរនូវប៉ុស្តិ៍ផ្តល់ដំណឹង ។ យើងមិនចង់ឈ្លោះប្រកែក ជាមួយឬខឹងពួកគេទេ ប៉ុន្តែ យើងក៏ស្រឡាញ់ធនធានធម្មជាតិរបស់យើងផងដែរ ។" |

| | |
|---|---|
| លោក ខាំ ភុនកុក (ជនជាតិគ្រឹង អាយុ ៥៤ ឆ្នាំ) ភូមិទាមលើ ស្រុកវឺនសៃ ទន្លេសេសាន | "ខ្ញុំសុំឱ្យអ្នកសាងសង់ទំនប់នៅក្នុងប្រទេសវៀតណាមធ្វើតាមចំណុចខាងក្រោមនេះ:<br>▪ ទោះជាតាមវិធីណាក៏ដោយ សូមធ្វើឱ្យទន្លេមានសភាពដូចកាលពីពេលមុន។<br>▪ ប្រសិនបើមានភ្លៀងខ្លាំង ហើយលោកចាំបាច់ត្រូវបញ្ចេញទឹកពីអាងទំនប់ សូមផ្តល់ដំណឹងឱ្យបានទាន់ពេលវេលាជូនដល់អ្នកភូមិផងអំពីការបញ្ចេញទឹក។ មកដល់ពេលនេះ ការផ្តល់ដំណឹងគឺមកដល់យឺតពេកទើបបានជាផ្តល់ដំណឹងដល់អ្នកភូមិមិនទាន់។ ជាធម្មតា អ្នកភូមិត្រូវបានគេផ្តល់ដំណឹងអំពីការបញ្ចេញទឹកក្រោយពេលមានទឹកជំនន់។ ហេតុនេះ គេគប្បីបង្កើតប្រព័ន្ធផ្តល់ព័ត៌មានមួយឱ្យបានសមស្រប ជាពិសេស គេគប្បីមានការទាក់ទងគ្នាតាមវិទ្យុ។<br>▪ សម្រាប់ពូជត្រីផ្សេងៗទាំងអស់ដែលយើងបានបាត់បង់ គឺដល់ពេលហើយដែលត្រូវធ្វើអភិរក្សត្រី។<br>▪ ផ្តល់សំណងឱ្យពួកយើងសម្រាប់ទ្រព្យសម្បត្តិខូចខាតនិងបាត់បង់ ដូចជាទូក មង និង ឧបករណ៍ផ្សេងៗទៀត ជាដើម។" |
| លោកស្រី ជាសុគន្ធ (ជនជាតិខ្មែរ អាយុ ៥២ ឆ្នាំ) ស្រុកតាវែង (ប្រហែល ៨៥ គីឡូម៉ែត្រ ខាងក្រោមខ្សែទឹកពីព្រំដែនវៀតណាម) | "នៅដើមខែ ធ្នូ ទន្លេគោក ហើយយើងអាចដើរឆ្លងបាន។ បាតទន្លេភាគច្រើនគឺគោកអស់។ ទទឹងទន្លេរួញចុះនៅសល់ត្រឹមតែ ១០ ម៉ែត្រ ប៉ុណ្ណោះ។ វាមានសភាពដូច នេះរយៈពេលបួនប្រាំថ្ងៃ ហើយបន្ទាប់មកទឹកទន្លេចាប់ផ្តើមឡើងយឺតៗរហូតដល់ កម្ពស់ធម្មតារបស់វា។" |

| | |
|---|---|
| <br>លោក រ៉ូម៉ង់ ម្លាក់ (ជនជាតិទំពួន អាយុ ៥៦ ឆ្នាំ)<br>ភូមិផាវដល់ ស្រុកអូរយ៉ាដាវ (ប្រហែល ៦ គីឡូម៉ែត្រ ខាងក្រោមខ្សែទឹកពីព្រំដែនវៀតណាម) | "ខ្ញុំបានអានរបាយការណ៍ EIA ទន្លេសេសាន [សេចក្តីសង្ខេបប្រតិបត្តិជាភាសាខ្មែរ] ប៉ុន្តែ ខ្ញុំចង់សុំឱ្យមានរៀបចំសិក្ខាសាលាមួយដើម្បីខ្ញុំអាចយល់បានថាតើវាមានន័យដូចម្តេច ។"<br><br>"កាលពីខែ សីហា [ឆ្នាំ ២០០៧] នៅពេលដែលយើងបានចាប់ផ្តើមច្រូតស្រូវ កម្ពស់ទឹកស្រាប់តែឡើងនិងស្រកយ៉ាងលឿន ។ នៅពេលកម្ពស់ទឹកឡើង មានការហូរច្រោះបាក់ច្រាំងទន្លេ ហើយខ្ញុំបាត់បង់ដីរបស់ខ្ញុំ ។ ប្រសិនបើវានៅតែបន្តអញ្ចឹងឆ្នាំក្រោយ ខ្ញុំប្រហែលជាត្រូវរើផ្ទះរបស់ខ្ញុំ ហើយភូមិខ្ញុំទាំងមូលក៏ប្រហែលជារើចេញឆ្ងាយពីទន្លេផងដែរ ។ ប៉ុន្តែ យើងធ្លាប់តែដាំបន្លែនៅតាមមាត់ទន្លេ ។ វាគឺជាប្រពៃណីរបស់យើង ។ ខ្ញុំមិនដឹងថាតើយើងនឹងធ្វើអ្វីទេប្រសិនបើយើងត្រូវរើផ្ទះ ។"<br><br>"កម្ពស់ទឹកនៅតែប្រែប្រួលរាល់ថ្ងៃ ។ ទឹកឡើងនៅពេលព្រឹក ហើយនៅពេលយប់ទឹកស្រកវិញ ។ ពេលដែលខ្ញុំវាស់ច្រាំងទន្លេ ការប្រែប្រួលគឺប្រហែល ៦ ម៉ែត្រ ។"<br><br>នៅថ្ងៃ ៥ ខែ ធ្នូ ប្រជាជននៅក្នុងភូមិបួននៅក្នុងស្រុកអូរយ៉ាដាវជិតព្រំដែនវៀតណាម ធ្លាក់ខ្លួនឈឺក្រោយពេលងូតទឹកនៅក្នុងទន្លេសេសាន ។ ប្រជាជនជាច្រើនបានធ្លាក់ខ្លួនឈឺជម្ងឺកមរមាស់ខ្លាំង ។ អ្នកខ្លះក៏ឈឺគ្រុនក្តៅផងដែរ ហើយអ្នកខ្លះទៀតមានដំបៅប៉ុនមេដៃលើសព្វរាងកាយ ។ ដំបៅនេះនៅស្ថិតស្ថេរពី ១២ ទៅ ១៣ ថ្ងៃ ។ មន្ទីរពេទ្យខេត្តបានមកជួយអ្នកភូមិ ។ ភូមិទាំងនេះគឺភូមិប៉ុតកាតាល់ ផាវដាល់តូច និង ផាវដាល់ធំ ។ |
| <br>លោក ប្រូ ណាន់ទៀង (ជនជាតិប្រាវ)<br>ភូមិកាលឹម ស្រុកវឺនសៃ (ប្រហែល ១១៥ | "ទន្លេក៏ប្រែប្រួលច្រើនដែរ ។ ក្នុងរដូវប្រាំង មានទឹកជំនន់ជានិច្ច ... ។ កម្ពស់ទឹកគឺមិនធម្មតា និង ឡើងស្រក ដែលធ្វើឱ្យពិបាកខ្លាំងក្នុងការធ្វើដំណើរ និង ចងទូកជាប់បង្គោល ។ ទឹកនៅក្នុងទន្លេគឺកខ្វក់ទាំងនៅក្នុងរដូវប្រាំងនិងរដូវវស្សា ហើយពេលណាយើងហែលក្នុងទឹកនេះ វាធ្វើឱ្យមានកន្ទួលរមាស់លើស្បែក ជាពិសេសនៅក្នុងរដូវប្រាំង ។ បន្លែបៃតងស្ទើរតែទាំងអស់ដែលដុះនៅតាមមាត់ទន្លេត្រូវបានបំផ្លាញ ហើយជួនកាល ដើមឈើដែលប្រជាជនប្រើប្រាស់សម្រាប់ធ្វើជាស្បៀងអាហារនិងថ្នាំសង្កូវ ធ្លាក់ចូលទៅក្នុងទន្លេដោយសារការខូចខាតដែលកើតមានឡើងលើច្រាំងទន្លេ [ការហូរច្រោះដីបាក់ច្រាំងទន្លេ] ។ ការផ្លាស់ប្តូរចំពោះទន្លេទាំងនេះ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើរបៀបរស់នៅរបស់យើង ដោយសារពេល |

| | |
|---|---|
| គីឡូម៉ែត្រ ខាងក្រោមខ្សែទឹកពីព្រំដែន)<br>លោក ទៀង បានរស់នៅតាមដងទន្លេសេសាន អស់រយៈពេល ៣០ ឆ្នាំ | ដែលទឹកឡើងនិងស្រក វាធ្វើឱ្យសំណាញ់និងមងរបស់យើងរហែក ។ ដោយសារទឹកត្រូវបានគេធ្វើឱ្យកខ្វក់នៅក្នុងរដូវប្រាំង វាគឺជាការលំបាកនិងមានគ្រោះថ្នាក់ខ្លាំងក្នុងការដងទឹកពីទន្លេដើម្បីប្រើប្រាស់ ។ ជួនកាល ខ្ញុំឃើញត្រីងាប់អណ្តែតនៅក្នុងទឹក ហើយខ្ញុំមិនដឹងថាមកពីហេតុអីទេ ។" |
| <br>លោកស្រី មឹក ញ៉ុម (ជនជាតិប្រៅ អាយុ ៥៧ ឆ្នាំ) ភូមិកោះពុង ស្រុកតាវែង ទន្លេសេសាន | "បច្ចុប្បន្ន អ្នកភូមិកំពុងជួបប្រទះការលំបាកជាច្រើននៅក្នុងជីវិតរបស់ខ្លួន ។ ពួកគេចំណាយពេលដាក់មង ប៉ុន្តែ ពុំមានត្រី ។ វាមិនដូចកាលពីដប់ឆ្នាំមុនទេ ។ យើងក៏ជួបការលំបាកផងដែរជាមួយនឹងប្រពៃណីរបស់យើងក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ ។ ទន្លេនេះគឺសំខាន់ណាស់សម្រាប់វប្បធម៌របស់ខ្ញុំ ។ យើងមិនអាចងូតទឹកនៅក្នុងទន្លេ ហើយយើងមិនអាចធ្វើពិធីប្រពៃណីលើដីខ្សាច់មាត់ទន្លេឡើយ ដោយសារខ្លាចទឹកជន់ ។ ទន្លេសេសានក៏ផ្តល់បញ្ហាដល់សុខភាពមនុស្សផងដែរ ។ ពូជត្រីខ្លះត្រូវបាត់បង់ ហើយការដាំបន្លែតាមមាត់ទន្លេនៅពេលនេះគឺធ្វើមិនបានទេ ។" |

**២. លោក ធាម ប៊ុនស្រ៊ុន (រូបកណ្តាលខាងមុខនៅក្នុងរូបថតខាងក្រោម) សមាជិករដ្ឋសភា បានទស្សនាភូមិនានាដែលរងផលប៉ះពាល់ពីទំនប់ នៅក្នុងស្រុកតាវែង ខែ ធ្នូ ឆ្នាំ ២០០៧ ។**

